ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ELECTRICITE DU CAMBODGE

អគ្គិសនីកម្ពុជា

លេខ : ០៤៦២ អកក.គគស.ធប

# សេចក្តីជូនដំណឹង
## ស្តីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជា ត្រូវការជ្រើសរើសបុគ្គលិក ចំនួន ០៣ រូប ដើម្បីចូលបម្រើការងារនៅ ការិយាល័យបច្ចេកទេសចែកចាយ នៃនាយកដ្ឋានអាជីវកម្មចែកចាយ ដូចខាងក្រោម :

*- **លក្ខណៈសម្បត្តិបេក្ខជន** :

- បេក្ខជនទាំង ០២ ភេទ, ត្រូវមានអាយុចាប់ពី ១៨ ដល់ ៣៥ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.I.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90% = ១,៤៧៩,០៦០ រៀល ឡើងទៅ
- កម្រិតជំនាញ : សញ្ញាប័ត្រវិស្វករអគ្គិសនី ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel, និង AutoCad
- ភាសាអង់គ្លេស : ចេះអាចប្រើការបានល្អ ។

*- **បេក្ខជនត្រូវមកដាក់ពាក្យ និង ភ្ជាប់មកជាមួយនូវ** :

- ពាក្យសុំចូលបម្រើការងារ មានបិទតែមប្រ៊ី( ១.០០០ រៀល) ចំនួន ០១ ច្បាប់
- ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ ចំនួន ០១ ច្បាប់
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬអាចយក សៀវភៅគ្រួសារ ឬអត្តសញ្ញាណប័ណ្ណ( ច្បាប់ចម្លង មានបញ្ជាក់ពី សាលារាជធានីភ្នំពេញ ឬសាលាខេត្ត ) ឬលិខិតបញ្ជាក់ទីលំនៅ ចុះហត្ថលេខាពីខណ្ឌ-ស្រុក ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់កិរិយាមារយាទ ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់សុខភាព(ចេញដោយនាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ)ចំនួន ០១ ច្បាប់
- ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ មានបញ្ជាក់ពីសាលារាជធានីភ្នំពេញ ឬសាលាខេត្ត ចំនួន ០១ ច្បាប់
- តារាងពិន្ទុ (TRANSCRIPT) ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់ ឬ ច្បាប់ចម្លងសញ្ញាប័ត្រផ្សេងៗ (បើមាន) ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់ពីបទពិសោធន៍ការងារ (បើមាន) ចំនួន ០១ ច្បាប់

*- **ទីកន្លែងទទួលពាក្យ** : សាលប្រជុំអគារ C ជាន់ទី៣ នៃអគ្គិសនីកម្ពុជា
ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៤ រៀងរាល់ថ្ងៃធ្វើការ

- ពេលព្រឹក ចាប់ពីម៉ោង ០៨ : ០០ ដល់ម៉ោង ១១ : ៣០
- ពេលល្ងាច ចាប់ពីម៉ោង ១៤ : ០០ ដល់ម៉ោង ១៧ : ០០
- ពាក្យសុំចូលបម្រើការងារ ត្រូវប្រើប្រាស់គំរូ មានបោះត្រាសម្គាល់របស់ អគ្គិសនីកម្ពុជា ។

*- **ព័ត៌មានផ្សេងៗ** : សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល ទីស្នាក់ការកណ្តាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៤

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**
អគ្គនាយករង

អេង_គន្ធា